# ហេតុអ្វីបានជាការពង្រឹងភាពធន់នៅជនបទ ដើម្បីឆ្លើយតបនឹងចំណាកស្រុកដោយសារការប្រែប្រួលអាកាសធាតុមានសារៈសំខាន់?

“មូលហេតុចម្បងនៃការចំណាកស្រុកគឺបញ្ហាហិរញ្ញវត្ថុ... អ្នកភូមិពឹងផ្អែកលើទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការ ពីព្រោះមិនមានប្រព័ន្ធធារាសាស្ត្រ... ជនចំណាកស្រុកមិនមានដីសម្រាប់ធ្វើកសិកម្ម... ជនចំណាកស្រុកស្វែងរកការងារធ្វើនៅទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀត។”

- បទសម្ភាសន៍ជនបង្គោល ខែកក្កដា ឆ្នាំ២០២៣

---

## ស្កេនទីនេះ

ដើម្បីអានរបាយការណ៍បន្ថែម

## Scan here!

To read the full report

© ២០២៥ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI

រចនាដោយ សូ លីហុង និង រស់ ច័ន្ទរល័ក្ខ

Australian Aid
PONLOK CHOMNES
The Asia Foundation
IOM UN MIGRATION
ASIA REGIONAL MIGRATION PROGRAM
CDRI Cambodia Development Resource Institute

## ហេតុអ្វីបានជាការពង្រឹងភាពធន់នៅជនបទដើម្បីឆ្លើយតបនឹងចំណាកស្រុកដោយសារការប្រែប្រួលអាកាសធាតុមានភាពសំខាន់?

**១០% នៃGDP** ធ្លាក់ចុះនៅឆ្នាំ **២០៥០** ដោយសារការប្រែប្រួលអាកាសធាតុ

**១,១ លាន នាក់** ប្រហែលជា **៦,៧៤%** នៃចំនួនប្រជាជនកម្ពុជាសរុបជា **ជនចំណាកស្រុក**

ការប្រែប្រួលអាកាសធាតុជំរុញឱ្យមានការធ្វើចំណាកស្រុកនៅតាមជនបទនៃប្រទេសកម្ពុជា ដោយសារការកត្តាសេដ្ឋកិច្ច និងជីវភាពរស់នៅ ដែលបង្កឡើងដោយព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរនិងបន្ថែមបន្ទុកដល់មនុស្សចាស់។ បុរស និងស្ត្រីទទួលរងផលប៉ះពាល់ផ្សេងៗ ពីការប្រែប្រួលអាកាសធាតុខុសៗគ្នា តាមរយៈការផ្លាស់ប្តូរការងារ ធនធាន និងតួនាទីក្នុងសង្គម។

## មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុសំខាន់ៗទាំងបួន ដែលប៉ះពាល់សហគមន៍ជនបទ

- ការឡើងកម្តៅ ៩៣,៣៣%
- ខ្យល់កន្ត្រាក់ ៨៧,៩៦%
- គ្រោះរាំងស្ងួត ៦៣,៨៦%
- ទឹកជំនន់ ៤៣,៦៣%

សហគមន៍តាមជនបទប្រឈមមុខនឹងការគំរាមកំហែងពីបរិស្ថានក្នុងកម្រិតផ្សេងៗគ្នា។ ជាមធ្យម ពួកគេត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការឡើងកំដៅខ្លាំង បន្ទាប់មកមានខ្យល់បក់ខ្លាំង គ្រោះរាំងស្ងួត និងទឹកជំនន់។

## លក្ខណៈនៃការធ្វើចំណាកស្រុក

### ជនចំណាកស្រុក




### ប្រភេទនៃចំណាកស្រុក










## តើការធ្វើចំណាកស្រុកមានទំនាក់ទំនងនឹងការប្រែប្រួលអាកាសធាតុបែបណា?

ការប្រែប្រួលអាកាសធាតុនាំឱ្យមានការខ្វះខាតទឹក និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតកម្មកសិកម្ម បន្ថយប្រាក់ចំណូលរបស់កសិករនៅជនបទ នឹងប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ ការបាត់បង់ប្រាក់ចំណូលបង្កឡើងដោយការខូចខាតផលដំណាំដែលបណ្តាលមកពីព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរគឺជាមូលហេតុមួយនៃការធ្វើចំណាកស្រុក។

### កត្តាដែលជំរុញឱ្យមានការធ្វើចំណាកស្រុក

| | |
|---|---|
| កត្តាសេដ្ឋកិច្ច | ៥៨,៥៨% |
| កត្តាសង្គម និងវប្បធម៌ | ២៨,៣៣% |
| កត្តាបរិស្ថាន | ៥,៤០% |
| កត្តាស្ថាប័ន និងនយោបាយ | ៤,២០% |
| កត្តាប្រជាសាស្ត្រ | ៣,៤០% |

កត្តាសេដ្ឋកិច្ចសង្គមនិងវប្បធម៌គឺជាកត្តាសំខាន់ដែលបង្កឱ្យមនុស្សធ្វើចំណាកស្រុក។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ បណ្តាលឱ្យបាត់បង់ទ្រព្យសម្បត្តិនិងផលដំណាំជំរុញឱ្យមានភាពក្រីក្រការជាប់បំណុល និងការធ្វើចំណាកស្រុក ដើម្បីស្វែងរកឱកាសការងារកាន់តែប្រសើរ។

## ដំណោះស្រាយរបស់សហគមន៍មូលដ្ឋាននឹងផលប៉ះពាល់អាកាសធាតុ

សហគមន៍មូលដ្ឋានជាទូទៅខ្ចីលុយពីសាច់ញាតិ ឬមិត្តភ័ក្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ហើយធ្វើចំណាកស្រុកទៅធ្វើការនៅពេលដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីផលប៉ះពាល់អាកាសធាតុ។




### អនុសាសន៍

ការបណ្តុះបណ្តាលស្តីពី**ការអនុវត្តកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ**នឹងផ្តល់អត្ថប្រយោជន៍ដល់កសិករ និងជួយពួកគេបង្កើនការដាំដុះ លើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយការធ្វើចំណាកស្រុក។

កម្មវិធីអភិវឌ្ឍន៍ជំនាញដូចជា**ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**(TVET) នឹងបង្កើតឱកាសការងារដែលធន់នឹងអាកាសធាតុនៅក្នុងសហគមន៍ ជាពិសេសសម្រាប់ស្ត្រី និងយុវជនមកពីគ្រួសារងាយរងគ្រោះ។

### លទ្ធភាពទទួលបានធនធានដោយសហគមន៍ជនបទ

កសិកម្មគឺជាសកម្មភាពបង្កើតប្រាក់ចំណូលដ៏សំខាន់។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពទទួលបានធនធានទឹកនៅមានកម្រិតដែលរារាំង ដល់ផលិតភាពកសិកម្ម។ ទិន្នផលកសិកម្មទាប គួបផ្សំនឹងកង្វះការងារក្នុងស្រុកលើកជំរុញឱ្យមនុស្សធ្វើចំណាកស្រុកដើម្បីស្វែងរកការងារដែលកាន់តែប្រសើរជាងមុន។

- ប្រព័ន្ធធារាសាស្ត្រ **២០,៨៦%**
- ទឹកស្អាត **៤១,២៦%**

### អនុសាសន៍

**ប្រព័ន្ធធារាសាស្ត្រដែលមានភាពប្រទាក់ក្រឡាគ្នា និងធន់នឹងអាកាសធាតុ**អនុញ្ញាតឱ្យកសិករអាចធ្វើស្រែបានពីររដូវ និងបង្កើនទិន្នផលដំណាំរបស់ពួកគេ។ ដោយមានទឹកគ្រប់គ្រាន់ កសិករអាចប្តូរពីការអនុវត្តកសិកម្មបែបបុរាណទៅទំនើបដែលធន់នឹងអាកាសធាតុនិងផ្តល់ទិន្នផលខ្ពស់ដូច្នេះហើយអាចបង្កើនសន្តិសុខស្បៀងនៅក្នុងសហគមន៍របស់ពួកគេ។

### ការគាំទ្ររបស់សហគមន៍

| មិនគ្រប់គ្រាន់ | អព្យាក្រឹត | គ្រប់គ្រាន់ |
|---|---|---|
| ៥៤,៤៩% | ៣០,១៣% | ១៣,២៣% |

សហគមន៍មូលដ្ឋានទទួលបានការគាំទ្រមិនទាន់ទទួលបានការគាំទ្រពេញលេញពីអាជ្ញាធរមូលដ្ឋាន។ទន្ទឹមនឹងនេះការចូលរួមរបស់ពួកគេក្នុងការអភិវឌ្ឍន៍ឃុំសង្កាត់ និងដំណើរការធ្វើសេចក្តីសម្រេចនៅតែមានកម្រិតទាប។

### អនុសាសន៍

លើកកម្ពស់ការចូលរួមរបស់មូលដ្ឋានជាពិសេសក្រុមជនងាយរងគ្រោះនិងការចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ ដំណើរការធ្វើសេចក្តីសម្រេចចិត្តស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ទាំងនេះអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានធនធាន ចំណេះដឹង និងព័ត៌មាន ហើយអាចបង្កើនសមត្ថភាពត្រៀមខ្លួនរបស់សហគមន៍។

ក្រាហ្វិកនេះគឺផ្អែកលើការសិក្សាដែលធ្វើឡើងដោយអ្នកស្រាវជ្រាវ CDRI នៅខេត្តក្រចេះ មណ្ឌលគិរី និងស្ទឹងត្រែង ក្នុងអំឡុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២៣ បង្ហាញពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក។